នស / រកត / ០១០២/០០១

# ព្រះរាជក្រឹត្យ

## ស្តីពី

## លក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស

## យើង

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី និងដោយមានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១

# ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ដែលត្រូវបានចាត់ថ្នាក់ ចូលក្នុងប្រភេទ ខ ដូចមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

មន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៣.-**

មន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសមានភារកិច្ចជាជំនួយការដល់មន្ត្រីការទូតជាន់ខ្ពស់ ហើយមានឧបនិស្ស័យក្នុងការបំពេញមុខងារក្នុងតំណែង ដឹកនាំអង្គភាពថ្នាក់មធ្យមនៅក្នុងក្រសួង និងនៅស្ថានតំណាងនានា នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ។

## ជំពូកទី ២
## ឋានន្តរស័ក្តិ និងមុខតំណែងនៃក្របខ័ណ្ឌ

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសមាន ៣ ឋានន្តរស័ក្តិ ៖

- នាយក្រមការការបរទេស មាន ៦ ថ្នាក់
- ក្រមការដើមខ្សែការបរទេស មាន ១០ ថ្នាក់
- ក្រមការការបរទេស មាន ១៤ ថ្នាក់

**មាត្រា ៥ .-**

១- នៅរដ្ឋបាលកណ្តាលរបស់ក្រសួង ៖

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ ក្រមការដើមខ្សែការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខតំណែង ជា ៖

- អនុប្រធានការិយាល័យ
- និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនា-សម្ព័ន្ធរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ នាយក្រមការការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខតំណែង ជា ៖

- ប្រធានការិយាល័យ
- និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនា-សម្ព័ន្ធរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

២- នៅស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ៖

មន្ត្រីរាជការ នៃក្របខ័ណ្ឌមន្ត្រី ក្រមការការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខតំណែង ជា ៖

- អនុព័ន្ធ អនុព័ន្ធរងស្ថានទូត ភ្នាក់ងារកុងស៊ុល ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ ក្រមការដើមខ្សែការបរទេស អាចកាន់មុខតំណែង ជា ៖

- អនុកុងស៊ុល ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ នាយក្រមការការបរទេស អាចកាន់មុខតំណែង ជា ៖

- កុងស៊ុល លេខាធិការទី២ លេខាធិការទី៣ ។

## ជំពូកទី ៣
## ការជ្រើសរើស និងការបណ្តុះបណ្តាលដំបូង

**មាត្រា ៦ .-**

ការជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងក្នុងចំណោមបេក្ខជន ជាមន្ត្រីរាជការ និង ឬក្នុងចំណោមនិស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជានិស្សិត ត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៧ .-**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវធ្វើចំពោះបេក្ខជនដែលមានសញ្ញាប័ត្រយ៉ាងទាប មធ្យមនីតិសាស្ត្រ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ និងមានអាយុយ៉ាងច្រើន ២៥ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។ អាយុនេះអាចរំកិលពី ២៥ឆ្នាំឡើងដល់ ៣០ឆ្នាំ ស្របតាមមាត្រា១១ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវធ្វើចំពោះមន្ត្រីរាជការទាំងឡាយរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលស្ថិតយ៉ាងទាបបំផុតក្នុងថ្នាក់លេខ១១ នៃក្របខ័ណ្ឌប្រភេទ គ និងមានអាយុច្រើនបំផុត ៤០ឆ្នាំ ។

ចំពោះមន្ត្រីរាជការរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាប័ត្រភាគទី ២ បូកនឹងពីរឆ្នាំសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សាដែលមានសញ្ញាប័ត្រ អាចប្រឡងចូលក្នុងក្របខ័ណ្ឌនេះបានដោយពុំគិតពីល័ក្ខខ័ណ្ឌឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុយ៉ាងច្រើនបំផុត ៤០ឆ្នាំ ។

**មាត្រា ៨.-**

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និង ឬក្នុងចំណោមនិស្សិតមានឋានៈជាសិស្សមន្ត្រីក្រមការការបរទេស ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ។

## ជំពូកទី ៤
## កម្មសិក្សា និងការតាំងស៊ប់

**មាត្រា ៩.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីក្រមការការបរទេសត្រូវបានចាត់អោយបំរើការងារនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយត្រូវបានតែងតាំងជាមន្ត្រីក្រមការការបរទេសកម្មសិក្សាការី ដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីក្រមការការបរទេសកម្មសិក្សាការីទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយ ដែលមានរយៈពេល ដូចខាងក្រោម ÷

១- ១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីនិស្សិត

២ - ៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការដែលពុំស្ថិតក្នុងក្របខ័ណ្ឌប្រភេទ ក ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ដែលស្ថិតក្នុងក្របខ័ណ្ឌប្រភេទ ក បំរើការងារក្នុងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាមន្ត្រី ដែលចែងក្នុងចំណុចទី១ និងចំណុចទី ២ ខាងលើ ដែលធ្វើកម្មសិក្សាបានល្អត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិ ក្រមការការបរទេស ។

ក្នុងករណីចាំបាច់ អាចតម្រូវអោយបន្តកម្មសិក្សាបន្ថែមទៀត ដែលមានរយៈពេលអតិបរមាត្រឹម១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង៦ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការបំពេញកម្មសិក្សាបន្ថែមនេះត្រូវលុបឈ្មោះចេញ ប្រសិនបើចេញមកពីនិស្សិត ឬមួយត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌដើមវិញ ប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលសំរាប់អតីតភាពការងារ ។ ករណីខាងលើនេះ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីក្រមការការបរទេស ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ១៤ នៃឋានន្តរស័ក្តិក្រមការការបរទេស ។

មន្ត្រីក្រមការការបរទេស ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការត្រូវបញ្ចូលទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិក្រមការការបរទេស នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ១០.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការការបរទេសរួចហើយ មន្ត្រីក្រមការការបរទេសទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួនតាមបែបបទដូចបានកំណត់ក្នុងមាត្រា២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦
## ការតម្លើងថ្នាក់ និងការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១១.-**

មន្ត្រី នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ មានដូចខាងក្រោម ÷

១- គោរពវិន័យការងារបានត្រឹមត្រូវ

២- មានចំណេះភាសាបរទេស ច្បាស់លាស់

៣-មានស្មារតីទទួលខុសត្រូវ

៤- សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ

៥- មានសីលធម៌ល្អ ។

ការតម្លើងថ្នាក់ នៃមន្ត្រីរាជការក្នុងក្របខ័ណ្ឌនេះត្រូវគិតក្នុងសមាមាត្រ បីភាគបួន ក្នុងវេនជ្រើសរើស និងមួយភាគបួនតាមវេនអតីតភាព ហើយត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ១២ .-**

គោលការណ៍ នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍បៀវត្សខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលទំនេរនៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុង ឬក្រៅប្រទេស ។

ការតម្លើងថ្នាក់ និងការតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ១៣.-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែការបរទេស តែមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ១១ នៃឋានន្តរស័ក្តិ ក្រមការការបរទេស ។

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយក្រមការការបរទេស តែមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ៧ នៃឋានន្តរស័ក្តិ ក្រមការដើមខ្សែការបរទេស ។

ការតម្លើងទៅក្នុងឋានន្តរស័ក្តិមួយខ្ពស់ជាងអាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីសំរាប់កាន់មុខតំណែងស្របតាមឋានន្តរស័ក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា៩ នៃលក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា ១៤ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស និងតម្លៃឯកតា នៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី ៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.-**

អាណត្តិបំរើការងារ នៃមន្ត្រីក្រមការការបរទេសនៅបរទេស ត្រូវកំណត់រយៈពេលបីឆ្នាំ ។ ក្នុងករណីចាំបាច់ អាណត្តិនេះ អាចពន្យារបានមួយឆ្នាំម្តង តែមិនត្រូវលើសពីរយៈពេលបីឆ្នាំឡើយ ។

**មាត្រា ១៦.-**

មន្ត្រីក្រមការការបរទេស បំរើការងាររហូតដល់អាយុ៥៨ឆ្នាំ ទើបចូលនិវត្តន៍ ។ ចំពោះការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ១៧.-**

មន្ត្រីក្រមការការបរទេស ដែលមានសញ្ញាប័ត្របរិញ្ញាប័ត្រ ឬ សញ្ញាប័ត្រសមមូលត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

**មាត្រា ១៨.-**

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីក្រមការការបរទេស ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ១៩**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងនៅស្ថានតំណាងនានា នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ២០**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមករា ឆ្នាំ ២០០២*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសម្ដេច**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

*៣៧៧-០៥-០១-០០០១*

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល